ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៧៤៦ កសក

រាជធានីភ្នំពេញ, ថ្ងៃទី.១០....ខែ.មីនា....ឆ្នាំ ២០១៦

សូមគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

កម្មវត្ថុ៖ របាយការណ៍អំពីស្ថានភាពនៃការបំពេញបែបបទនាំចេញអង្ករក្នុងរយៈពេល២ខែដើមឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាបថា នៅរយៈពេល២ខែដើមឆ្នាំ២០១៦នេះ ស្ថានភាពនៃការនាំចេញអង្ករទៅក្រៅប្រទេសដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបានដោយផ្អែកលើប្រព័ន្ធទិន្នន័យគ្រឹះភូតគាមអនាម័យជាតិ National Phytosanitary database (NPD/GDA from 07:00/01.01.2016 to 17:00/29.02.2016) ដែលជាតួលេខនៃការនាំចេញតាមរយៈការរៀបចំវេចខ្ចប់គ្រប់ចំនួនរួចជាស្រេច និងបានឆ្លងកាត់ការត្រួតពិនិត្យភូតគាមអនាម័យដើម្បីនាំចេញមានដូចខាងក្រោម ៖

១ -ស្ថានភាពនៃការនាំចេញអង្ករ៖

- បរិមាណអង្ករនាំចេញមានចំនួន៩៥.៩៤៥តោន មានការកើនឡើងចំនួន២២.៣៤៨តោន (+៣០,៤%) លើសបរិមាណនាំចេញរយៈពេល២ខែដើមឆ្នាំ២០១៥ ដែលនាំចេញបានតែ៧៣.៥៩៧តោន។ ក្នុងនោះបរិមាណនាំចេញក្នុងខែកុម្ភៈនេះមានដល់ ៥១.៩១២តោនដែលមានកំណើន១៤.២៣៦តោន(+៣៧,៨%)លើសខែកុម្ភៈឆ្នាំមុន (សូមបង្ហាញជូនក្នុងតារាងទី១នៃឧបសម្ព័ន្ធ)

- អង្ករក្រអូបគ្រប់ប្រភេទមានបរិមាណនាំមុខគេដែលមានកំណើនកើនឡើងរហូតដល់៤៦.១៩៩តោន ស្មើនឹង៤៨,១% អង្ករ ស គ្រប់ប្រភេទមានចំនួន ៤៤.១២១តោនស្មើនឹង៤៦% និងអង្ករចំហុយ ៥.៦២៥តោនស្មើនឹង ៥,៩% នៃបរិមាណអង្ករសរុបដែលនាំចេញក្នុងរយៈពេល២ខែដើមឆ្នាំនេះ។ ក្នុងចំណោមអង្ករក្រអូបនោះអង្ករផ្កាម្លិះ (Jasmine rice) និងផ្កាវិដួលជាប្រភេទអង្ករដែលបាននាំចេញច្រើនជាងគេមានបរិមាណរហូតដល់២៨,៣០១ស្មើនឹង ២៩,៤% (លំដាប់ទី១) អង្ករក្រអូបចម្រុះ(នាងក្រអូប នាងសយ និងពូជដទៃ)មានបរិមាណ ១២,៩១២ ស្មើនឹង ១៣,៥% (លំដាប់ទី២) អង្ករក្រអូបនាងម្លិះមានបរិមាណ២.៩៩៤ ស្មើនឹង៣.១% (លំដាប់ទី៣) អង្ករភ្លីមានបរិមាណ៩៦៨តោន ស្មើនឹង ១% (លំដាប់ទី៤) អង្ករក្រអូបសរីរាង្គមានបរិមាណ ៥៩៤តោនស្មើនឹង០.៦% (លំដាប់ទី៥) និងសូមាលីមានបរិមាណ៨៣០តោន ស្មើនឹង០.៤% (លំដាប់ទី៦) (សូមបង្ហាញជូនក្នុងតារាងទី២នៃឧបសម្ព័ន្ធ)

-អង្ករកម្ពុជាបាននាំចេញទៅកាន់ទិសដៅចំនួន៤៤ប្រទេស ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ (២០.៤៣៦ តោន) ប្រទេសបារាំងឈរលំដាប់ទី២ (១២.៤៥៤តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (១០.៧៨៤តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៤ (៦.០០២តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៥ (៤.៦៣៦តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៦ (៤.៥៨៦តោន) ប្រទេសអ៊ីតាលីឈរលំដាប់ទី៧ (៣.៥៧៦តោន) ប្រទេសបែលហ្ស៊ីកឈរ លំដាប់ទី៨ (៣,៤៥២តោន) ប្រទេសឆេកឈរលំដាប់ទី៩ (៣,៣៧៩តោន) និងប្រទេសហុងគ្រីឈរលំដាប់ទី១០ (៣,២១៥តោន)

- បរិមាណអង្ករដែលនាំចេញទៅកាន់ប្រទេសជាទិសដៅសហគមន៍អឺរ៉ុប២៨ប្រទេសមាន បរិមាណសរុប ៦២.២៩៦តោន (៦៤,៩%) ទិសដៅអាស៊ាន៣ប្រទេសមានបរិមាណសរុប ៨.៥៦៥តោន (៨,៩%)

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 32

និងទិសដៅដទៃទៀត១៧ប្រទេសមានបរិមាណសរុប២៥.០៨៤តោន (២៦,១%) (សូមបង្ហាញជូនក្នុងតារាងទី៣នៃឧបសម្ព័ន្ធ)

-ការនាំចេញអង្ករមាន ៥៩ក្រុមហ៊ុន (កើនឡើងចំនួន១១ក្រុមហ៊ុនធៀបនឹងខែមករា) ដែលបរិមាណអង្ករនាំចេញត្រូវបាននាំមុខគេ ដោយ៖ (ទី១).ក្រុមហ៊ុន Nicoline មានចំនួន១២.៤៨១តោន (ទី២).ក្រុមហ៊ុន Khmer Food មានចំនួន១១.៧៣៨តោន (ទី៣).ក្រុមហ៊ុន Amru Rice មានចំនួន៨.២៦៩តោន (ទី៤).ក្រុមហ៊ុន BAITANG មានចំនួន៥.១៦១តោន (ទី៥).ក្រុមហ៊ុន City Rice import Export មានចំនួន៥.០២៣តោន (ទី៦) ក្រុមហ៊ុន T.O.T មានចំនួន៤.៧៦៧តោន (ទី៧).ក្រុមហ៊ុន International Rice Trading មានចំនួន៤.៧០៦តោន (ទី៨).ក្រុមហ៊ុន Cristal Rice ចំនួន៤.៧០១តោន (ទី៩).Golden Rice ចំនួន៤.៤៨៥តោន (ទី១០).ក្រុមហ៊ុន Signatures Of Asia មានចំនួន៣.៤១០តោន (សូមបង្ហាញជូនក្នុងតារាងទី៤នៃឧបសម្ព័ន្ធ)។ បរិមាណអង្ករដែលនាំចេញដោយក្រុមហ៊ុនធំៗទាំង១០មានចំនួនសរុប រហូត ៦៤.៧៤១ តោនស្មើនឹង៦៧,៥% នៅពេលដែលក្រុមហ៊ុន៤៩ដទៃទៀតនាំចេញបានតែ ៣១.២០៤ តោនស្មើនឹង ៣២,៥% ប៉ុណ្ណោះ។

២-សន្និដ្ឋាន៖

បរិមាណអង្ករនាំចេញសរុបក្នុងរយៈពេល២ខែដើមឆ្នាំ២០១៦ មានចំនួន ៩៥.៩៤៥តោន ដែលបរិមាណនេះ មានកំណើនប្រមាណ៣០,៤% ធៀបនឹងបរិមាណនាំចេញរយៈពេល២ខែដើមឆ្នាំ២០១៥។

លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ ដែលជាសេនាធិការរបស់ក្រុមការងារទី៩ បន្តពង្រីកវិសាលភាព ប្រសិទ្ធភាពដើម្បីបំពេញតួនាទីក្នុងការបង្កើនការយល់ដឹងដល់អ្នកពាក់ព័ន្ធ (សមត្ថកិច្ចដែលពាក់ព័ន្ធនឹងបែបបទនាំចេញអង្ករ ក្រុមហ៊ុននាំចេញអង្ករ រោងម៉ាស៊ីនកិនស្រូវ និងកែច្នៃអង្ករ ក្រុមហ៊ុនដឹកជញ្ជូន។ ល ។ ដែលកំពុងមានសកម្មភាពនាំចេញអង្ករ) ក្នុងការរៀបចំទុកដាក់ស្រូវ អង្ករមុននាំចេញប្រកបដោយគុណភាព និងបំពេញបែបបទឲ្យបានសមស្របដោយអនុលោមតាមលក្ខខ័ណ្ឌតម្រូវរបស់ប្រទេសនាំចូល និងរាល់កិច្ចព្រមព្រៀងជាធរមានរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយប្រទេសនាំចូល។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំបាទសូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយក្តីអនុគ្រោះ។

សូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

មណ្ឌិត វ៉ុក រ៉ាប៊ុន

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានកសិកម្ម
- នាយកដ្ឋានផែនការនិងស្ថិតិ "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ: របាយការណ៍អំពីស្ថានភាពនៃការនាំចេញអង្ករកម្ពុជាប្រចាំខែកុម្ភៈឆ្នាំ២០១៦

(ANNEX: THE REPORT ON CAMBODIAN RICE EXPORT STATUS IN FABRUARY, 2016)

(Base on NPD/GDA from 07:00/01.01.2016 to 17:00/29.02.2016 and all number are English punctuation)

តារាងទី១. បរិមាណអង្ករកម្ពុជាដែលបាននាំចេញប្រចាំខែ ក្នុងឆ្នាំ ២០១២ - ២០១៦, គិតជាតោន

(Table1. Quantity of Cambodian Rice have been Exported by months of 2012-2016, in tones)

	Month/ Year	2012	2013	2014	2015	2016	VARIATION
1	មករា (January)	9,703	25,726	21,536	35,921	44,033	+22.60%
2	កុម្ភៈ (February)	14,417	24,089	27,037	37,676	51,912	+37.80%
	Sub-Total for 2 months	24,120	49,815	48,573	73,597	95,945	+30.40%
3	មិនា (March)	12,310	45,413	35,757	75,867		
4	មេសា (April)	15,036	23,276	35,961	51,719		
5	ឧសភា (May)	13,115	28,350	27,971	41,842		
6	មិថុនា (June)	13,426	29,105	29,666	40,800		
7	កក្កដា (July)	20,527	31,411	26,060	28,492		
8	សីហា (August)	15,530	29,358	29,871	29,819		
9	កញ្ញា (September)	15,169	29,395	35,511	26,969		
10	តុលា (October)	16,967	28,031	35,418	39,064		
11	វិច្ឆិកា (November)	25,189	37,855	31,137	48,748		
12	ធ្នូ (December)	34,328	46,847	51,136	81,479		
GRAND TOTAL		205,717	378,856	387,061	538,396		

តារាងទី២. ប្រភេទអង្ករកម្ពុជាដែលបាននាំចេញក្នុង២ខែដើមឆ្នាំ ២០១៦, គិតជាតោន

(Table 2. Type of Cambodian Rice have been Exported in February 2016, in tones)

ប្រភេទអង្ករ / TYPE OF RICE		មករា / JANUARY	កុម្ភៈ / FRABRUARY	សរុប (TOTAL) MT	%
I. អង្ករក្រអូប /JASMINE/ FRAGRANT RICE:					
1	ចម្រុះ (F.SENKRAOB, NEANG SAUY....)	5,888	7,024	12,912	13.50
2	នាងមួិស (F. NEANG MALIS)	1,787	1,207	2,994	3.10
3	សូមាលី .(F. SOMALY)	214	216	430	0.40
4	ផ្កាឫស្សី /ផ្កាមួិស/ (J.PHKA RUMDUOL/ MALIS)	14,672	13,629	28,301	29.40
5	សរីរាង្គ (J.ORGANIC)	414	180	594	0.60
6	ភ្លឺ . (F. PEARL)	48	920	968	1.00
	SUB-TOTAL	23,023	23,176	46,199	48.10
II.អង្ករសគ្រាប់វែង /WHITE LONG GRAIN RICE:					
1	ចម្រុះគ្រាប់វែង (LONG GRAIN)	18,310	24,878	43,188	45.00
2	ប្រណិតគ្រាប់វែង (PREMIUM LONG GRAIN)	445	488	933	1.00
	SUB-TOTAL	18,755	25,366	44,121	46.00
III.អង្ករចំហុយគ្រាប់វែង/ LONG GRAIN PABOILLED:					
1	ចំហុយគ្រាប់វែង (LONG GRAIN PABOILLED)	2,255	3,370	5,625	5.90
	SUB-TOTAL	2,255	3,370	5,625	5.90
GRAND TOTAL		44,033	51,912	95,945	100.00

តារាងទី៣.ទិសដៅនៃការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល២ខែដើមឆ្នាំ ២០១៦, គិតជាតោន

(Table 3. Export Destination of Cambodian Rice 2 Month of 2016, in tones)

	ប្រទេសទិសដៅ	មករា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា	សរុប
	COUNTRY DESTINATION	JAN	FEB	MAR	APR	MAY	JUN	TOTAL
	I.សមាជិកសហគមន៍អឺរ៉ុប /EUROPEAN UNION							
1	FRANCE	6,386	6,068					12,454
2	POLAND	5,538	5,246					10,784
3	NETHERLAND	2,503	2,133					4,636
4	UNITED KINGDOM	2,074	2,512					4,586
5	ITALY	1,912	1,664					3,576
6	BELGIUM	1,017	2,435					3,452
7	CZECH REPUBLIC	1,232	2,147					3,379
8	HUNGARY	1,300	1,915					3,215
9	GERMANY	1,631	1,499					3,130
10	ROMANIA	2,764	196					2,960
11	BULGARIA	900	1,250					2,150
12	SPAIN	847	1,073					1,920
13	PORTUGAL	50	1,304					1,354
14	SWEEDEN	596	520					1,116
15	GREECE	361	636					997
16	CROATIA	450	425					875
17	DENMARK	215	485					700
18	LATIVA		400					400
19	LITHUANIA		300					300
20	SLOVENIA		96					96
21	CYPRUS	24	72					96
22	AUSTRIA	72						72
23	FINLAND	24						24
24	IRELAND		24					24
	SUB-TOTAL	**29,896**	**32,400**					**62,296**
	II. សមាជិកអាស៊ាន/ASEAN MEMBER STATE							
1	MALAYSIA	2,736	3,266					6,002
2	BRUNEI	1,974						1,974
3	SINGAPORE	418	171					589
	SUB-TOTAL	5,128	3,437					**8,565**
	III.ទិសដៅផ្សេងទៀត /OTHERS DESTINATION							
1	CHINA	6,999	13,437					20,436
2	GABON	518	1,034					1,552
3	HONG KONG	373	310					683
4	TURKY		500					500
5	RUSSIAN FED	200	200					400
6	AUSTRALIA	229	168					397
7	ANGOLA	300	50					350
8	IRAQ	230						230
9	USA	57	143					200
10	CANADA	20	42					62
11	MAYOTTE	50						50
12	SWITZERLAND	26	72					98
13	NEWZEALAND		45					45
14	LEBANON		25					25
15	NAMIBIA		25					25
16	ISRAEL		24					24
17	JAPAN	7						7
	SUB-TOTAL	9,009	16,075					**25,084**
	GRAND TOTAL	**44,033**	**51,912**					**95,945**

តារាងទី៤.ក្រុមហ៊ុននិងបរិមាណដែលបានធ្វើការនាំចេញអង្ករកម្ពុជា២ខែដើមឆ្នាំ ២០១៦,គិតជាតោន និង %

(Table 4.Cambodian Rice Exporters and export quantity in 2 Months of 2016, in tones & % share)

	ក្រុមហ៊ុននាំចេញអង្ករ	មករា	កុម្ភៈ	មីនា	មេសា	ឧសភា	សរុប (TOTAL)	
	RICE EXPORTERS	JAN	FEB	MAR	APR	MAY	MT	%
1	NIKOLINE INVESTMENT CO., LTD.	4,656	7,825				12,481	13.01
2	KHMER FOODS GROUP CO.,LTD.	5,161	6,577				11,738	12.23
3	AMRU RICE (CAMBODIA) CO.,LTD	4,342	3,927				8,269	8.62
4	BAITANG (KAMPUCHEA) PLC.	4,046	1,115				5,161	5.38
5	CITY RICE IMPORT EXPORT CO., LTD.	2,069	2,954				5,023	5.24
6	T.O.T (TRUST OUR TRADE) CO., LTD.	2,411	2,356				4,767	4.97
7	INTERNATIONAL RICE TRADING (CAMBODIA) CO.,LTD.	2,223	2,483				4,706	4.90
8	CRISTAL RICE (Kampuchea) co., ltd.	1,903	2,798				4,701	4.90
9	GOLDEN RICE (CAMBODIA) CO.,LTD.	2,736	1,749				4,485	4.67

10	SIGNATURES OF ASIA CO.,LTD	1,396	2,014				3,410	3.55
11	GOLDEN DAUN KEO RICE MILL CO., LTD	425	2,920				3,345	3.49
12	HUNG HIEP (CAMBODIA) CO., LTD	1,886	842				2,728	2.84
13	SSCORP(CAMBODIA) CO.,LTD	806	1,518				2,324	2.42
14	W.K.R TRADING CO.,LTD	826	1,247				2,073	2.16
15	INDOCHINA RICE MILL LIMITED	951	1,101				2,052	2.14
16	THMOR KORL RICE IMPORT EXPORT CO., LTD	920	920				1,840	1.92
17	LOR EAK HENG SEK MEAS RICE CO., LTD	987	749				1,736	1.81
18	KHY THAY CORPORATION CO.,LTD.	754	754				1,508	1.57
19	WHITE GOLD IMPORT EXPORT CO,. LTD.	255	1,200				1,455	1.52
20	ANDURIZ (CAMBODGE) SARL	470	675				1,145	1.19
21	CK RICE TRADING CO., LTD.	615	516				1,131	1.18
22	Mekong oryza trading co., ltd.		1,124				1,124	1.17
23	ANGKOR KASEKAM ROONGROEUNG CO.,LTD.	443	446				889	0.93
24	APSARA RICE (CAMBODIA) CO., LTD	258	543				801	0.83
25	Amru and Hanwha international co., ltd	298	294				592	0.62
26	PHOU POY DEVELOPMENT IMPORT EXPORT CO., LTD	399	145				544	0.57
27	BATTAMBANG RICE INVESTMENT CO., LTD	400	133				533	0.56
28	CAPITAL FOOD INVESTMENT IMPORT EXPORT CO., LTD.		517				517	0.54
29	GUOHONG (CAMBODIA) INDUSTRY Co.,LTD.		500				500	0.52
30	FED RICE BATTAMBANG LTD	100	350				450	0.47
31	VONG BUNHENG IMPORT EXPORT CO., LTD	321	120				441	0.46
32	COMMODITY IN FOCUS CO., LTD.	194	225				419	0.44
33	LIM KHEANG HOUT IMPORT EXPORT CO., LTD.	100	248				348	0.33
34	BOOST RICHE (CAMBODIA) CO., LTD.	297					297	0.31
35	GLOBAL ECOLOGICAL RICE (CAMBODIA) CO., LTD	289					289	0.30
36	MEI JING RICE (CAMBODIA) CO., LTD		248				248	0.26
37	BAYON CEREAL CO., LTD	97	150				247	0.26
38	DOMNAK TEUK GROUP CO.,LTD	144	72				216	0.23
39	AROMA RICE IMPORT EXPORT CO.,LTD	71	50				121	0.13
40	CAM-GRAIN DEVELOPMENT CO., LTD.	100	20				120	0.13
41	SAHAKREAS CEDAC LTD	60	60				120	0.13
42	OU TONG DEVELOPMENT (CAMBODIA) CO., LTD	92	23				115	0.12
43	Branch of CHONGQING(FT&ECP) GROUP Co., Ltd.	100					100	0.10
44	LIM HENG LEAP TRADING CO.,LTD	50	50				100	0.10
45	OVERSEAS FOODS IMPORT EXPORT CO.,LTD	50	48				98	0.10
46	SOMA TRADING COMPANY LIMITED	97					97	0.10
47	AIMS GRAIN ASIA LTD.	92					92	0.10
48	KAMPONG THOM RICE MILL LIMITED.		75				75	0.08
49	BAYON JASMINE RICE CO.,LTD		48				48	0.05
50	CAVIFOODS co., ltd (Cambodia Vietnam foods)		48				48	0.05
51	MILIN RICE (CAMBODIA) IMPORT EXPORT CO.,LTD		47				47	0.05
52	JING MI RICE MILL CO., LTD	46					46	0.05
53	YAMCHANN RICE CO., LTD.	46					46	0.05
54	LK INTERNATIONAL GROUP PLC.		41				41	0.04
55	MUFAVOR INTERNATIONAL (CAMBODIA) INC.		25				25	0.03
56	SOK KEO IMPORT EXPORT CO., LTD	24					24	0.03
57	CAMBODIAN li shine international trade co.,ltd		22				22	0.02
58	KHUN NGUON rice export co., ltd.	20					20	0.02
59	HUA FENG YUAN rice vermicelli (Cam) industrial co.,ltd	7					7	0.01
	GRAND TOTAL	44,026	51,912				95,945	100.00

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១៦

អ្នករៀបចំសរុបទិន្នន័យ

ឌិន នរិទ្ធ

បានឃើញ និង ឯកភាព

ប្រធានលេខាធិការដ្ឋាន

ច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ

បណ្ឌិត ហ៊ាន វណ្ណហាន